**ព្រះរាជសន្ទរកថា**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**

**ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ក្នុងពិធីបុណ្យរុក្ខទិវា**

នៅភូមិត្រពាំងឃ្លៃ ឃុំបឹងកន្ទួត ស្រុកក្រគរ ខេត្តពោធិសាត់ ,ថ្ងៃទី ០៩ កក្កដា ឆ្នាំ ២០០៩

-សូមក្រាបថ្វាយបង្គំព្រះមេគណ និង ព្រះថេរានុថេរៈគ្រប់ព្រះអង្គ ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់

-សម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាទីមេត្រី

-ឯកឧត្តម លោកជំទាវ ឯកអគ្គរាជទូត ឯកអគ្គរដ្ឋទូត លោក លោកស្រី និង ប្រិយមិត្តបរទេស ទាំងអស់ជាទីមេត្រី

-ជនរួមជាតិ លោកតា លោកយាយ មាមីង បងប្អូន និង ក្មួយៗ ជាទីនឹករលឹក និងគោរពស្រឡាញ់ ដ៏ជ្រាលជ្រៅបំផុត

ខ្ញុំព្រះករុណា ខ្ញុំ មានសេចក្តីសោមនស្សរីករាយ បានមកថ្វាយបង្គំ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ ព្រមទាំងបានជំរាបសួរសុកទុក្ខ ដោយសេចក្តីនឹករលឹកបំផុតចំពោះ ឯកឧត្តម លោកជំទាវ លោក លោកស្រី លោកតា លោកយាយ មាមីង បងប្អូន និងក្មួយៗជាជនរួមជាតិទាំងអស់នៃខេត្តពោធិសាត់ នៅក្នុងឱកាសដ៏នក្ខត្តឫក្សនៃការប្រារព្ធពិធី **បុណ្យរុក្ខទិវា** ដ៏ឧត្តុង្គឧត្តមនេះ ។

ខ្ញុំព្រះករុណា ខ្ញុំ សូមអរព្រះគុណយ៉ាងជ្រាលជ្រៅ ចំពោះព្រះវត្តមានរបស់ព្រះថេរានុត្ថេរៈ និងសូមអរគុណ សម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី លោកតា លោកយាយ មាមីង បងប្អូន និងក្មួយៗ ជាជនរួមជាតិទាំងអស់ដែលបានចំណាយពេលវេលាដ៏មានតម្លៃ បាននិមន្ត និងអញ្ជើញមកចូលរួមក្នុងឱកាសដ៏ថ្លៃថ្លានេះ។ ទន្ទឹមនឹងនេះ ខ្ញុំព្រះករុណាខ្ញុំសូមកោតសរសើរក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ និងអាជ្ញាធរដែនដីនៃខេត្តពោធិសាត់ ដែលបានសហការរៀបចំប្រារព្ធពិធី **បុណ្យរុក្ខទិវា** នាឱកាសនេះ នៅក្នុងតំបន់ **សហគមន៍ព្រៃឈើត្រពាំងឃ្លៃ** នៃស្រុកក្រគរ ខេត្តពោធិ៍សាត់ ដើម្បីបង្កើតឡើងវិញនិងបង្កើនធនធានព្រៃឈើឱ្យកាន់តែប្រសើរឡើង ប្រែក្លាយមូលដ្ឋាននេះ ឱ្យទៅជាតំបន់មានទេសភាពល្អ ប្រកបដោយគំរបពណ៌បៃតង កាន់តែស្រស់ត្រកាលឡើងថែមទៀត។ សកម្មភាពដ៏ឧត្តុង្គឧត្តមនេះ បានឆ្លុះបញ្ចាំងឱ្យឃើញនូវការចូលរួមចំណែកយ៉ាងខ្លាំងក្លា របស់ប្រជាជាតិខ្មែរយើង ក្នុងស្មារតីជួយថែរក្សា ការពារ គ្រប់គ្រង និងប្រើប្រាស់ធនធានព្រៃឈើជាតិ ឱ្យមាននិរន្តរភាពជារៀងរហូតតទៅ ។

នៅក្នុងឱកាសដ៏ថ្លៃថ្លានេះខ្ញុំព្រះករុណា ខ្ញុំសូមនាំនូវព្រះរាជទានសេចក្តីនឹករលឹក សេចក្តីបណ្តាំផ្ញើសួរសុខទុក្ខ និងសេចក្តីស្រឡាញ់ដ៏ជ្រាលជ្រៅបំផុត អំពី **ព្រះករុណាព្រះមហាវីរក្សត្រ ព្រះវររាជបិតាជាតិខ្មែរ**

**និង សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់ មកប្រគេនព្រះថេរានុត្ថេរៈ គ្រប់ព្រះអង្គ និងជូន សម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី លោកតា លោកយាយ មាមីង បងប្អូន និងក្មួយ ៗ ជាជនរួមជាតិទាំងអស់ ដែលបាននិមន្តនិង អញ្ជើញមកចូលរួមក្នុងពិធីបុណ្យដ៏មហោឡារិកនេះ និងសូមជូនពរបវរមហាប្រសើរ ចំពោះបងប្អូនប្រជារាស្ត្រទូទាំងប្រទេស ដែលកំពុងប្រឹងប្រែងកសាងជីវភាពរស់នៅ សូមបានប្រកបទៅ ដោយសេចក្តីសុខ សេចក្តីចំរើន និងសុភមង្គលគ្រប់ប្រការ ។

ខ្ញុំព្រះករុណា ខ្ញុំ សូមអរគុណយ៉ាងជ្រាលជ្រៅ ចំពោះឯកឧត្តមអភិបាលខេត្តពោធិ៍សាត់ ដែលបានអានទូវសុន្ទរកថាស្វាគមន៍មានអត្ថន័យដ៏ច្បាស់លាស់ បានបង្ហាញទូវការរីកចំរើនលើគ្រប់វិស័យក្នុងខេត្តពោធិ៍សាត់ព្រមទាំងបានឆ្លុះបញ្ចាំងឱ្យឃើញទូវការដឹកនាំប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុនសែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង ការអនុវត្តទូវរាល់ភារកិច្ច របស់អាជ្ញាធរខេត្តគ្រប់លំដាប់ថ្នាក់ បានធ្វើឱ្យទឹកដីខេត្តពោធិសាត់ សំរេចបានទូវសមិទ្ធផល ជាច្រើនរួមចំណែកជួយកសាងជីវភាពជូនបងប្អូនប្រជារាស្ត្រទូទៅ ។

ក្នុងឱកាសនេះដែរ ខ្ញុំព្រះករុណាខ្ញុំ មានសេចក្តីរីករាយ សូមអរគុណចំពោះរបាយការណ៍ដ៏មាន អត្ថន័យរបស់ ឯកឧត្តម រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលបានលើកឡើងនូវលទ្ធផល ដែលសំរេចបានក្នុងវិស័យព្រៃឈើ និងការខិតខំយកចិត្តទុកដាក់ខ្ពស់ បំពេញភារកិច្ចតាមគោលនយោបាយចតុកោណដំណាក់កាលទី២ របស់រាជរដ្ឋាភិបាលកម្ពុជា ។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋបាលព្រៃឈើជាអ្នកអនុវត្តយ៉ាងសកម្មក្នុងការគ្រប់គ្រង ការប្រើប្រាស់ និងការអភិវឌ្ឍ ដោយផ្សារភ្ជាប់ទៅនឹងការការពារ ថែរក្សាធនធានព្រៃឈើឱ្យមាននិរន្តរភាព និងបានចាត់វិធានការយ៉ាងតឹងរឹង តាមការកំណត់នៃច្បាប់ស្តីពីព្រៃឈើ និងគោលនយោបាយព្រៃឈើជាតិ។ ទន្ទឹមនឹងនេះ បានជំរុញការដាំដើមឈើឡើងវិញកាន់តែខ្លាំងក្លាឡើងថែមទៀតនៅទូទាំងផ្ទៃប្រទេស ដែលសកម្មភាពនេះបានផ្តល់គុណប្រយោជន៍ច្រើនយ៉ាងក្នុងការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមនិងជួយទ្រទ្រង់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋផងដែរ។

ខ្ញុំព្រះករុណា ខ្ញុំតែងតែយកចិត្តទុកដាក់តាមដានការអភិវឌ្ឍវិស័យកសិកម្ម ដែលជាវិស័យអាទិភាពមួយរបស់រាជរដ្ឋាភិបាលកម្ពុជា។ នៅពេលបច្ចុប្បន្ននេះ ការងារបង្កបង្កើនផល មានការប្រែប្រួលច្រើនជាពិសេសបងប្អូនប្រជាកសិករ កំពុងតែចាប់អារម្មណ៍លើប្រពលវប្បកម្ម ដែលមានលក្ខណៈទំនើប ជាបណ្តើរៗហើយ ។ ជាក់ស្តែងទិន្នផលស្រូវ មានការកើនឡើងជាលំដាប់ពីមួយឆ្នាំទៅមួយឆ្នាំ ដូចជានៅឆ្នាំ ២០០៨កន្លងមកនេះ ព្រះរាជាណាចក្រកម្ពុជា សល់ស្រូវជាង ៣លានតោន ទោះបីមានបាតុភូតធម្មជាតិមិនល្អ ឬក៏មានឥទ្ធិពលនៃវិបត្តិហិរញ្ញវត្ថុពិភពលោកក៏ដោយ ។ ជាមួយនេះដែរ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទក៏បានធ្វើការអភិវឌ្ឍវិស័យជាអទិភាពនេះនៅទូទាំងប្រទេស ទទួលបានលទ្ធផលល្អប្រសើរ ដើម្បីជួយដោះស្រាយ សេចក្តីទុកលំបាក ក៏ដូចជាការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ បានជាបន្តបន្ទាប់ ។

-ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ ជាទីសក្ការៈខ្ពង់ខ្ពស់

-សម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី មាមីង បងប្អូន និងក្មួយៗជាទីមេត្រី

ធនធានព្រៃឈើបានផ្តល់សារប្រយោជន៍យ៉ាងច្រើនក្រៃលែងដល់សង្គមជាតិយើងតាំងពីដើមរៀងរហូតមក។ ព្រៃឈើពុំគ្រាន់តែមានតម្លៃខាងសេដ្ឋកិច្ច និង សង្គមប៉ុណ្ណោះទេ តែនៅមានតម្លៃខ្ពស់មិនអាចប៉ាន់ប្រមាណបាន ដូចជាជួយថែរក្សាលំនឹងបរិស្ថានធម្មជាតិ, ធ្វើឱ្យធាតុអាកាសមានភាពកាន់តែប្រសើរឡើងរក្សាបាននូវនិយ័តភាព ប្រភពទឹក ,ការពារទីជំរាល និងការពារជីវៈចំរុះផ្សេងៗជាដើម ។ សរុបមកព្រៃឈើគឺជាប្រភពដង្ហើមរស់របស់មនុស្ស និង សត្វ នៅលើភពផែនដីក្នុងពេលបច្ចុប្បន្ន និងក្នុងពេលអនាគតជារៀងដរាប ។ ដូច្នេះការប្រារព្ធពិធី**បុណ្យរុក្ខទិវា** នាពេលនេះពិតជាបានឆ្លុះបញ្ចាំងឱ្យឃើញនូវការខិតខំប្រឹងប្រែងរបស់ប្រជាជាតិយើងទាំមូល ក្នុងការប្រឈមមុខដោះស្រាយគ្រោះមហន្តរាយធម្មជាតិ នៅក្នុងតំបន់និង ពិភពលោក ព្រមទាំងបានបង្ហាញនូវស្មារតីទទួលខុសត្រូវលើជោគវាសនាអនាគតនៃមាតុភូមិរបស់យើង ។

ពិធី **បុណ្យរុក្ខទិវា** ជាវប្បធម៌ដ៏ថ្លៃថ្លារបស់ប្រជាជាតិកម្ពុជា មានតាំងពី **សម័យសង្គមរាស្ត្រនិយម** ហើយត្រូវបានបន្តជាប្រពៃណីរហូតមកដល់បច្ចុប្បន្ន និងតទៅអនាគត ដោយមានចែងនៅក្នុងច្បាប់ស្តីពីព្រៃឈើ ដែលជា **ទិវាពលកម្មដាំដើមឈើជាតិ** ត្រូវបានប្រារព្ធឡើងនៅ **ថ្ងៃទី ០៩ ខែកក្កដា** រៀងរាល់ឆ្នាំ ។ **ព្រះករុណាព្រះមហាវីរក្សត្រ ព្រះវររាជបិតាជាតិខ្មែរ និងសម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់ ព្រះអង្គតែងតែប្រោសព្រះរាជទានលើកទឹកចិត្ត និង បានយាងចូលរួមជាព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់ក្នុងពិធី **បុណ្យរុក្ខទិវា** នៅតាមខេត្តនានា។ ខ្ញុំព្រះករុណា ខ្ញុំ បាន ចូលរួមប្រារព្ធពិធីបុណ្យជាប្រពៃណីនេះ ដែលរៀបចំដោយរាជរដ្ឋាភិបាលកម្ពុជា ជារៀងរាល់ឆ្នាំ ពុំដែលអាក់ខានឡើយ ។ ខ្ញុំព្រះករុណា ខ្ញុំ សូមអបអរសាទរ និងគាំទ្រទាំងស្រុងចំពោះការខិតខំប្រឹងប្រែងយ៉ាងពេញទំហឹងរបស់រាជរដ្ឋាភិបាលកន្លងមក ជាពិសេសដំណើរការ អនុវត្តគោលនយោបាយកែទំរង់វិស័យព្រៃឈើបច្ចុប្បន្ន និងការរៀបចំកម្មវិធីព្រៃឈើជាតិ សំដៅការអភិវឌ្ឍវិស័យព្រៃឈើ ការអភិរក្ស និងការការពារធនធានព្រៃឈើ និងសម្បត្តិធម្មជាតិ ផ្សេងៗទៀតឱ្យ មានចិរភាពជារៀងរហូត ពីព្រោះធនធានទាំងអស់នេះ ពិតជាប្រភពផ្តល់នូវវិភាគទានជាអតិបរមា សំរាប់ចូលរួមកាត់បន្ថយភាពក្រីក្រ ជួយលើកស្ទួយជីវភាពប្រជារាស្ត្រផងដែរ ។

ទន្ទឹមនេះ ខ្ញុំព្រះករុណា ខ្ញុំ សូមអំពាវនាវដល់អង្គការជាតិ-អន្តរជាតិ ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាក់ពន្ធ័ទាំងអស់ត្រូវយកចិត្តដាក់បន្តធ្វើការផ្សព្វផ្សាយដល់បងប្អូន ដែលកំពុងប្រកបរបរចិញ្ចឹមជីវិត ដោយការធ្វើអាជីវកម្មព្រៃឈើខុសច្បាប់ ជាពិសេសបងប្អូនមួយចំនួនតូច នៅខេត្តពោធិសាត់ដែលកំពុងផលិតប្រេងម្រេះព្រៅភ្នំ ដែលជាសារធាតុអាចយកទៅផលិតជាគ្រឿងញៀនបាននោះ ឱ្យងាកមកប្រកបរបរកសិកម្មដើម្បីលើកស្ទួយជីវភាពគ្រួសារជំនួសវិញ ពីព្រោះការផលិតប្រេងម្រេះព្រៅភ្នំនេះមិនត្រឹមតែបំផ្លិចបំផ្លាញធនធានព្រៃឈើ បរិស្ថានធម្មជាតិ និងជីវៈចម្រុះយ៉ាងធ្ងន់ធ្ងរប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានបង្កឱ្យ គ្រោះថ្នាក់ធ្ងន់ធ្ងរដល់បុគ្គលផ្ទាល់ខ្លួន សង្គមគ្រួសារ សហគមន៍មូលដ្ឋាន និងសង្គមជាតិទាំងមូលទៀតផង ។

នៅក្នុងឱកាសដ៏ល្អប្រពៃនិងរីករាយបំផុត នៃពិធី**បុណ្យរុក្ខទិវា** នាពេលនេះ ខ្ញុំ ព្រះករុណា ខ្ញុំសូមអំពាវនាវ ចំពោះព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ និងបងប្អូនជនរួមជាតិទូទាំងប្រទេស សូមព្រះមេត្តា និងមេត្តារួបរួមគ្នា ជួយថែរក្សាការពារព្រៃឈើ និង ដាំដើមឈើល្អៗគ្រប់ប្រភេទឱ្យបានកាន់តែច្រើនឡើងនៅលើដីទំនេរសេសសល់ ទាំងឡាយ ទោះបីជាដីទីទួលខ្ពស់ក្ដី ឬជាដីទំនាបលិចទឹកក្ដី ដើម្បីអភិវឌ្ឍមាតុភូមិយើង និងធ្វើឱ្យបរិស្ថានបានល្អប្រសើរ ក្នុងន័យធ្វើឱ្យធនធាន រុក្ខផល ជលផល និងជីវៈចម្រុះគ្រប់ប្រភេទសម្បូរឡើងវិញ ដែលអាចជួយទ្រទ្រង់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋកម្ពុជាយើង ។ ក្នុងមួយឆ្នាំបើប្រជាពលរដ្ឋកម្ពុជាម្នាក់ៗគ្រប់រូប បានដាំកូនឈើបានមួយដើមនោះ យើងនឹងបានដើមឈើច្រើនលានដើម ដែលនឹងផ្ដល់ផលដល់កូនចៅយើង នៅពេលអនាគត ។ ទន្ទឹមនេះដែរ សូមមេត្តា រួមគ្នាសន្សំសំចៃ ក្នុងការប្រើប្រាស់ផល និងអនុផលព្រៃឈើគ្រប់ប្រភេទ ដើម្បីធានានិរន្តរភាពធនធានព្រៃឈើ ឱ្យបានគង់វង្ស តទៅ ។

ខ្ញុំ ព្រះករុណា ខ្ញុំ សូមអំពាវនាវ ដល់សហគមន៍អ្នកផ្ដល់ជំនួយជាតិ និងអន្តរជាតិ ព្រមទាំងដៃគូអភិវឌ្ឍរបស់កម្ពុជាទាំងអស់ សូមបន្តជួយឧបត្ថម្ភគាំទ្រហិរញ្ញវត្ថុនិងបច្ចេកទេស ដល់សកម្មភាពកែទម្រង់វិស័យព្រៃឈើដ៏ត្រឹមត្រូវ និងល្អប្រពៃរបស់រាជរដ្ឋាភិបាលកម្ពុជា ។

ខ្ញុំព្រះករុណា ខ្ញុំ សូមឧទ្ទិសឱ្យពិធី**បុណ្យរុក្ខទិវា** នេះជាបេសកកម្ម អភិវឌ្ឍមួយប្រកបដោយ គុណធម៌របស់មនុស្សជាតិក្នុងបុព្វហេតុការពារ និងរក្សានិរន្តរភាពនៃភពផែនដី ដើម្បីឱ្យមនុស្សជាតិបានរួចផុតពីគ្រោះថ្នាក់នៃការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយធម្មជាតិនានា ។ ទន្ទឹមនឹងនេះដែរ ខ្ញុំ ព្រះករុណា ខ្ញុំ សង្ឃឹមថា **សហគមន៍ព្រៃឈើត្រពាំងឈ្លៃ** នឹងទទួលខុសត្រូវខ្ពស់ក្នុងការដាំ និងថែរក្សាការពារព្រៃឈើក្នុងតំបន់នោះ ឱ្យដុះលូតលាស់ផ្ដល់ផលបានល្អ សមតាមបំណងប្រាថ្នា និង មានចិរភាពជារៀងរហូត ។

ជាទីបញ្ចប់ ខ្ញុំ ព្រះករុណា ខ្ញុំសូមប្រគេនពរព្រះមេគណ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ និងជូនពរ សម្ដេច ឯកឧត្តម លោកជំទាវ លោក លោកស្រី លោកតា លោកយាយ មាមីង បងប្អូន និងក្មួយៗ ជាជនរួមជាតិទាំងអស់ និងប្រិយមិត្តបរទេសទាំងអស់ សូមបានប្រកបនូវពុទ្ធពរ ទាំង ៤ ប្រការ កុំបីឃ្លៀងឃ្លាតឡើយ ។

**សូមអរព្រះគុណ និង សូមអរគុណ**